**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គំរូកិច្ចសន្យាផលិតកម្មកសិកម្ម

**ស្តីពី**

..........................................................

**រវាង**

**ភាគីអ្នកផលិតៈ**................................................

**និង**

**ភាគីអ្នកទិញៈ**..................................................

ធ្វើនៅ.............ថ្ងៃទី.............ខែ..............ឆ្នាំ..............

# គំរូកិច្ចសន្យាផលិតកម្មកសិកម្ម

## ស្ដីពី............................................

## រវាង

លោក/លោកស្រីឈ្មោះ..............................ភេទ.......អាយុ........មានតួនាទីជា..............................

អាសយដ្ឋានបច្ចុប្បន្ន.......................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ..................................ចុះថ្ងៃទី.......ខែ........ឆ្នាំ...........

លេខទូរស័ព្ទ................................. អ៊ីម៉ែលៈ..............................ប្រអប់សំបុត្រ..............................

តំណាងឲ្យ............................ដែលបានចុះបញ្ជីលេខ.......................ចុះថ្ងៃទី.......ខែ.........ឆ្នាំ........

មានការិយាល័យកណ្ដាលស្ថិតនៅ......................................................... ហៅថា **ភាគីអ្នកផលិត** ។

## និង

លោក/លោកស្រីឈ្មោះ..............................ភេទ.......អាយុ........មានតួនាទីជា..............................

អាសយដ្ឋានបច្ចុប្បន្ន.......................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ..................................ចុះថ្ងៃទី.......ខែ........ឆ្នាំ...........

លេខទូរស័ព្ទ................................. អ៊ីម៉ែលៈ..............................ប្រអប់សំបុត្រ..............................

តំណាងឲ្យ...................................................................ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃ

ព្រះរាជាណាចក្រកម្ពុជាលេខ................................................ចុះថ្ងៃទី.......ខែ............ឆ្នាំ............

មានការិយាល័យកណ្ដាលស្ថិតនៅ...............................................................ហៅថា **ភាគីអ្នកទិញ**។

## យោង

- អនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
- សារាចរណែនាំលេខ១៩៦សរណន.កសក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្ដីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

**ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌដូចខាងក្រោមៈ**

## ផ្នែកទី១

## លក្ខខណ្ឌទូទៅ

**ប្រការ១ .– កម្មវត្ថុនៃកិច្ចសន្យា**

ភាគីអ្នកទិញយល់ព្រមទទួលទិញផលិតផលពីភាគីអ្នកផលិតនូវប្រភេទផលិតផល.................

បរិមាណ...........................ដែលមានទីតាំង....................................................................

- ..........................................................................................................................

**ប្រការ២ .– ថិរវេលានៃការអនុវត្តកិច្ចសន្យា**

កិច្ចសន្យានេះចាប់ផ្ដើមថ្ងៃទី............ខែ...............ឆ្នាំ.......................... និងពេលវេលាបញ្ចប់ថ្ងៃទី............ខែ...........ឆ្នាំ.................. (កិច្ចសន្យាមានរយៈពេលខ្លី មធ្យម ឬ វែង អាស្រ័យលើអាយុកាលនៃប្រភេទដំណាំ រុក្ខជាតិ ឬ សត្វ ឬតាមការព្រមព្រៀងរបស់ភាគីទាំងពីរ)

- ..........................................................................................................................

# ផ្នែកទី២
# សិទ្ធិ និងភាតព្វកិច្ចរបស់គូភាគី

**ប្រការ៣ .– សិទ្ធិ និងភាតព្វកិច្ចរបស់ភាគីអ្នកផលិត**

- យល់ព្រមអនុវត្តតាមលក្ខខណ្ឌដែលបានស្នើឡើងដោយភាគីអ្នកទិញដូចមានចែងក្នុងកិច្ចសន្យា
- អនុញ្ញាតឲ្យបុគ្គលិកភាគីអ្នកទិញចូលពិនិត្យក្នុងទីតាំងរបស់ខ្លួនទៅតាមកម្មវិធីដែលបានព្រមព្រៀង
- ទទួលខុសត្រូវផ្គត់ផ្គង់ផលិតផលតាម ប្រភេទ បរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងប្រការ១ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨នៃកិច្ចសន្យានេះ
- ផ្ដល់ព័ត៌មានអំពីដំណើរការផលិតកម្ម (ពេលវេលាប្រមូលផល និងការផ្លាស់ប្ដូរទីកន្លែង...)
- រៀបចំបញ្ជីឈ្មោះក្រុមកសិករដែលចូលរួមអនុវត្តកិច្ចសន្យា(ករណីសមាជិកច្រើនចូលរួម)
- ទទួលខុសត្រូវសងការខូចខាតដល់ភាគីអ្នកទិញក្នុងករណីមិនបានអនុវត្តតាមលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យានេះ។
- ..........................................................................................................................

**ប្រការ៤ .– សិទ្ធិ និងភាតព្វកិច្ចរបស់ភាគីអ្នកទិញ**

- ផ្ដល់ការគាំទ្រនូវផ្នែកខ្លះ ឬ ទាំងស្រុងនៅក្នុងសង្វាក់ផលិតកម្ម (ឧទាហរណ៍ : ឥណទាន ពូជ ជី ចំណីសត្វ...) ដាំដុះ ឬ ចិញ្ចឹម ប្រសិនបើមានតម្រូវការពីភាគីអ្នកផលិត ដោយធានានូវគុណភាព បរិមាណ ប្រភេទ និងរយៈពេល ដែលត្រូវអនុវត្ត (ដូចមានចែងលម្អិតអំពីធាតុចូល ដែលផ្ដល់ដោយភាគីអ្នកទិញ ដែលសន្យាគាំទ្រដល់ភាគីអ្នកផលិតដូចមានក្នុងឧបសម្ព័ន្ធ២)
- ភាគីអ្នកទិញមានសិទ្ធិចូលពិនិត្យក្នុងទីតាំងរបស់ភាគីអ្នកផលិតដោយផ្ដល់ដំណឹងជាមុនដល់ភាគីអ្នកផលិត និងផ្ដល់ការណែនាំបច្ចេកទេស ការបណ្ដុះបណ្ដាល ស្របតាមលក្ខខណ្ឌបច្ចេកទេស(ដោយមានភ្ជាប់ជាមួយឯកសារបច្ចេកទេស) តាមការព្រមព្រៀង
- ទទួលខុសត្រូវទិញផលិតផលតាម ប្រភេទ បរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងប្រការ១ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨
- ទទួលខុសត្រូវសងការខូចខាតដល់ភាគីអ្នកផលិតក្នុងករណីមិនបានអនុវត្តតាមលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យានេះ។
- ..........................................................................................................................

# ផ្នែកទី៣

# ការអនុវត្តកិច្ចសន្យា

**ប្រការ៥ .– ពេលវេលាប្រមូលផល ទីកន្លែងដឹកជញ្ជូន និងការផ្ទុកទំនិញ**

- ការកំណត់ពេលវលាប្រមូលផល និងទីកន្លែងដឹកជញ្ជូនផលិតផល
- ការរៀបចំវិក័យប័ត្រប្រគល់ និងទទួលផលិតផល
- កំណត់ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន
- ភាគីអ្នកទិញត្រូវផ្តល់ភាពងាយស្រួលដល់ភាគីអ្នកផលិតក្នុងការដឹកជញ្ជូនផលិតផលចូលទីតាំងរបស់ខ្លួនឲ្យបានទាន់ពេលវេលា
- រាល់ការដឹកជញ្ជូនផលិតផលទៅកាន់រោងចក្រមានរូបភាពជាក្រុម ឬ ក៏សមាជិកម្នាក់ៗ អាចដឹកទៅរៀងៗខ្លួនបាន(ត្រូវមានការចរចាគ្នារវាងភាគីទាំងពីរ)
- ក្នុងករណីមានបញ្ហាលើការដឹកជញ្ជូនភាគីទាំងពីរត្រូវផ្តល់ដំណឹងអំពីបញ្ហាយឺតយ៉ាវនោះដល់ភាគីម្ខាងទៀត (ក្នុងរយៈពេល.............)
- ភាគីអ្នកទិញត្រូវរៀបចំប័ណ្ណសំគាល់សមាជិករបស់ភាគីអ្នកផលិតក្នុងការដឹកជញ្ជូនទំនិញទៅកាន់ទីតាំងរបស់ខ្លួន។ ពេលដឹកមកដល់ទីតាំងរបស់ភាគីអ្នកទិញម្តងៗ ភាគីអ្នកទិញ និងភាគីអ្នកផលិតត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ការដឹកជញ្ជូនចំនួនបីច្បាប់ ហើយត្រូវរក្សាទុកជាឯកសាររៀងៗខ្លួន។ ការកំណត់ និងទីកន្លែង ប្រគល់ ទទួលផលិតផលក្នុងប្រការ៥ នៃកិច្ចសន្យាមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៥។
- .......................................................................................................................

**ប្រការ៦ .– ការកំណត់គុណភាពផលិតផល**

- ការអនុវត្តជាក់ស្តែងក្នុងការកំណត់គុណភាពផលិតផល ផ្អែកលើការពិនិត្យជាក់ស្តែងដោយនៅទីតាំងផលិតកម្ម ឬ ការកំណត់គុណភាពផលិតផលនៅរោងចក្រតាមការព្រមព្រៀងរវាងភាគីទាំងពីរ។
- ការកំណត់ចំណាត់ថ្នាក់គុណភាពផលិតផល ត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរ (ដូចមានចែងលម្អិតក្នុងឧបសម្ព័ន្ធ៣)។
- .....................................................................................................................

**ប្រការ៧ .– ការកំណត់តម្លៃ**

- ការកំណត់តម្លៃអាស្រ័យនឹងគុណភាពផលិតផល ដែលបានត្រូវកំណត់ដោយមានការព្រមព្រៀងគ្នា
- ត្រូវមានការព្រមព្រៀងគ្នាក្នុងការកំណត់តម្លៃជាមុន ឬ អាស្រ័យលើតម្លៃទីផ្សារជាក់ស្តែងនៅពេលប្រមូលផល។ ជាទូទៅការកំណត់តម្លៃតាមទីផ្សារជាក់ស្តែងនៅពេលប្រមូលផលត្រូវផ្អែកទៅតាមតម្លៃក្នុងតំបន់របស់ខ្លួន។ត្រូវមានការកំណត់រូបមន្តតម្លៃទៅតាមពេលវេលាឲ្យបានច្បាស់លាស់ ។

- .......................................................................................................................

**ប្រការ៨ .– ការទូទាត់**

- នៅពេលទំនិញដែលភាគីអ្នកផលិតដឹកទៅដល់ទីតាំងរបស់ភាគីអ្នកទិញ ត្រូវមានការទូទាត់ភ្លាម ឬរងចាំរយៈពេល.......(ណាមួយអាស្រ័យលើការព្រមព្រៀង)។ ការទូទាត់អាចធ្វើតាមរយៈធនាគារ ឬ តាមការទូទាត់ជាសាច់ប្រាក់អាស្រ័យលើការព្រមព្រៀងរបស់ភាគីទាំងពីរ
- បើតាមរយៈធនាគារ ភាគីអ្នកទិញត្រូវចេញសក្ខីប័ត្រចំណាយ និងមូលប្បទានប័ត្រទៅឲ្យភាគីអ្នកផលិតជាតំណាងឬចេញឲ្យសមាជិកម្នាក់ៗតាមការព្រមព្រៀង។ ភាគីអ្នកផលិតត្រូវបង្កើតលេខគណនេយ្យធនាគាររបស់ខ្លួន
- រាល់ការចំណាយលើសេវាផ្ទេរប្រាក់ជាបន្ទុករបស់ភាគីអ្នកទិញ
- ប្រភេទប្រាក់ចរាចរ ត្រូវមានការកំណត់ឯកភាពគ្នា ឲ្យបានច្បាស់លាស់ក្នុងកិច្ចសន្យានេះ
- ការទូទាត់ថ្លៃត្រូវបានធ្វើឡើងដូចមានចែងលម្អិតក្នុងឧបសម្ព័ន្ធ៤។
- .......................................................................................................................

**ប្រការ៩ .– ករណីប្រធានសក្តិ**

- ក្នុងករណីមានហេតុការណ៍កើតឡើង ដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ភាគីណាមួយ ដូចជា អគ្គីភ័យ សត្វល្អិតបំផ្លាញ ឬ ជំងឺរាតត្បាតធ្ងន់ធ្ងរ ខ្យល់ព្យុះ រញ្ជួយដី ទឹកជំនន់ គ្រោះរាំងស្ងួត សង្គ្រាម ការធក់ប្លន់ ឬ អំពើវិទ្ធង្សនា។ល។ ភាគីរងគ្រោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរពាក់ព័ន្ធដែលស្ថិតនៅជិតកន្លែងកើតហេតុ និងភាគីម្ខាងទៀតក្នុងរយៈពេលមិនលើស០៣ថ្ងៃ ។
- ប្រសិនបើរយៈពេលនៃប្រធានសក្តិនេះបន្តលើសពី(**ចំនួន**....**ថ្ងៃ**) កិច្ចសន្យានេះត្រូវបញ្ចប់ដោយពុំមានកាតព្វកិច្ចទទួលខុសត្រូវដោយភាគីណាមួយឡើយ។
- នៅពេលដែលករណីប្រធានសក្តិបានកន្លងផុតទៅ ភាគីទាំងពីរអាចអនុវត្តបន្តចំពោះផលិតផលដែលនៅសេសសល់ ដោយធ្វើការព្រមព្រាងគ្នាជាថ្មី(ដូចដែលបានរៀបរាប់មានភ្ជាប់ក្នុងឧបសម្ព័ន្ធ៦)។
- .......................................................................................................................

**ប្រការ១០ .– ការបញ្ចប់កិច្ចសន្យា**

- **កិច្ចសន្យានឹងត្រូវបានបញ្ចប់បន្ទាប់ពីបានអនុវត្តពេញលេញ**តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង
- ចំពោះភាគីណាមួយដែលមិនបានអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាភាគីនោះត្រូវមានសំណងការខូចខាតដល់ភាគីម្ខាងទៀតទៅតាមការបង់ខាតជាក់ស្តែង។
- .......................................................................................................................

**ប្រការ១១ .– ការដោះស្រាយវិវាទ**

- ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយគ្នាជាមុន។

- ក្នុងករណី មិនអាចដោះស្រាយបាននោះវិវាទនឹងបញ្ជូនទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការដោះស្រាយបន្ត។
- ករណីនៅតែមិនអាចដោះស្រាយបានទៀតនោះវិវាទនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការសម្របសម្រួលនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីដោះស្រាយ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការសម្របសម្រួលស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺជាការសម្រេចចុងក្រោយ។
- ..........................................................................................................................

**ប្រការ១២ .– ការបង្កើតកិច្ចសន្យា និងភាសា**

កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរពិតប្រាកដ ដោយសេរី និងគ្មានការគំរាមគំហែង។ កិច្ចសន្យានេះត្រូវបានយកភាសាខ្មែរជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន០៥(ប្រាំ)ច្បាប់ មានតម្លៃស្មើគ្នា ដោយតម្កល់ទុកនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(នាយកដ្ឋានកសិ-ឧស្សាហកម្ម) ចំនួន ០១ច្បាប់, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ចំនួន ០១ច្បាប់, សាលាឃុំ/សង្កាត់ ចំនួន ០១ច្បាប់, ភាគីអ្នកផលិត ចំនួន ០១ច្បាប់,ភាគីអ្នកទិញ ចំនួន ០១ច្បាប់។

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទាំងអស់ត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចព្រមព្រៀង ៖

១២.១. ឧបសម្ព័ន្ធ១: បញ្ជីឈ្មោះសមាជិក និងលទ្ធភាពរបស់ភាគីអ្នកផលិតចូលរួមអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

១២.២. ឧបសម្ព័ន្ធ២: សេចក្តីបរិយាយអំពីការគាំទ្រធាតុចូលដោយភាគីអ្នកទិញ

១២.៣. ឧបសម្ព័ន្ធ៣: ការកំណត់ចំណាត់ថ្នាក់គុណភាព

១២.៤. ឧបសម្ព័ន្ធ៤: បែបបទនៃការទូទាត់ថ្លៃសម្រាប់ផលិតផល

១២.៥. ឧបសម្ព័ន្ធ៥: កាលកំណត់ និងទីកន្លែង ប្រគល់ ទទួលផលិតផលក្នុងប្រការ ៥ នៃកិច្ចសន្យា

១២.៦. ឧបសម្ព័ន្ធ៦: ការអនុវត្តនៅពេលមានករណីប្រធានសក្តិកើតឡើង

- ..........................................................................................................................

ធ្វើនៅ.........................ថ្ងៃទី..........ខែ...........ឆ្នាំ........

| **តំណាងភាគី អ្នកផលិត** | **សាក្សី** | **សាក្សី** | **តំណាងភាគី អ្នកទិញ** |
| --- | --- | --- | --- |
| ………………………. | ………………………. | ………………………. | ………………………. |
| (ស្នាមម្រាមដៃសាមីខ្លួន) | (ស្នាមម្រាមដៃសាមីខ្លួន) | (ស្នាមម្រាមដៃសាមីខ្លួន) | (ស្នាមម្រាមដៃសាមីខ្លួន) |

បានឃើញ និងឯកភាព

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កន្លែងតំកល់ឯកសារៈ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម)
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត .........
- សាលាឃុំ/សង្កាត់ ...............
- ភាគីអ្នកផលិត
- ភាគីអ្នកទិញ

**ឧបសម្ព័ន្ធ១**

បញ្ជីឈ្មោះសមាជិក និងលទ្ធភាពរបស់ភាគីអ្នកផលិតចូលរួមអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

| ល.រ No | នាម និងគោត្តនាម Name | ទីតាំង Location | ផលិតផល Products | ទំហំផ្ទៃដី Land Size | បរិមាណ លក់ Quantity sale (kg) | ស្នាមម្រាមដៃ/ Trumping |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ធ្វើនៅ..................ថ្ងៃទី................ខែ....................ឆ្នាំ២០......

**តំណាងភាគីអ្នកផលិត**

(ស្នាមម្រាមដៃសាមីខ្លួន)

លេខ:..........................

បានឃើញ និងបញ្ជាក់ថា:

ឈ្មោះ............................................................នេះពិតជា

................................នៃ................................................

និងពិតជាកំពុងស្នាក់នៅបច្ចុប្បន្ននៅផ្ទះលេខ.......................

ផ្លូវ....................ភូមិ/មណ្ឌល...........................................

ឃុំ/សង្កាត់.......................ក្រុង/ស្រុក/ខណ្ឌ.......................

រាជធានី/ខេត្ត.................................................................

នេះប្រាកដមែន។

ធ្វើនៅ.....................ថ្ងៃទី........ខែ..............ឆ្នាំ២០......

ហត្ថលេខា និងត្រា

**មេឃុំ/ចៅសង្កាត់**

**ឧបសម្ព័ន្ធ២**

សេចក្ដីបរិយាយអំពីការគាំទ្រធាតុចូលដោយភាគីអ្នកទិញ

| ល.រ | បរិយាយ (ធាតុចូល) | បរិមាណ | តម្លៃ (ឯកតា) | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ធ្វើនៅ..................ថ្ងៃទី................ខែ....................ឆ្នាំ២០......

**តំណាងភាគីអ្នកផលិត**

(ស្នាមម្រាមដៃសាមីខ្លួន)

**ឧបសម្ព័ន្ធ៣**

ការកំណត់ចំណាត់ថ្នាក់គុណភាព

សំគាល់១ : គុណភាព និងស្តង់ដារនៃផលិតផល

.......................................................................................................................................................................

.......................................................................................................................................................................

សំគាល់២ : ភាគីទាំង២ព្រមព្រៀងទិញផលិតផលតាមកិច្ចព្រមព្រៀងតាមប្រការ៦ នៃកិច្ចសន្យាដូចខាងក្រោម៖

| ល.រ | ចំណាត់ថ្នាក់គុណភាព | បរិមាណ (គ.ក្រ) | តម្លៃ (រៀល/គ.ក្រ) | សរុប (រៀល) | សំគាល់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ភាគីទាំងពីរព្រមព្រៀងគ្នាកែតម្រូវតម្លៃផលិតផល ដោយបន្ថែមថ្លៃលើតម្លៃទីផ្សារក្នុងអត្រាមិនលើសពី (            %) (            ) នៃតម្លៃកិច្ចព្រមព្រៀង

## ឧបសម្ព័ន្ធ ៤

បែបបទនៃការទូទាត់ថ្លៃសម្រាប់ផលិតផល

☐ ១ .ទូទាត់ថ្លៃភ្លាមៗ ក្រោយប្រគល់ និងទទួលផលិតផល

☐ ២. ទូទាត់ថ្លៃបន្ទាប់ពីប្រគល់ ទទួលផលិតផលតាមរយៈ

២.១.កាលវិភាគទូទាត់ថ្លៃខាងក្រោមៈ

| ដំណាក់កាលប្រគល់ | កាលវិភាគទូទាត់ថ្លៃ |
|---|---|
| ១.រយៈពេល..........ថ្ងៃ នៃថ្ងៃប្រគល់ ទទួលផលិតផល, បន្ទាប់ពីថ្ងៃទី........................ ដល់ថ្ងៃទី............................................ | ១.១.ទូទាត់ថ្លៃលើកទីពីរចំនួន....................................................(រៀល) គុណភាពលេខ(១,២,៣) ..........................................ក្នុងបរិមាណផលិតផល.......................................(គ.ក្រ,ក្បាល........) នៅថ្ងៃទី...................................................................................................................................... ១.២.ទូទាត់ថ្លៃលើកទីពីរចំនួន....................................................(រៀល) គុណភាពលេខ(១,២,៣) ..........................................ក្នុងបរិមាណផលិតផល.......................................(គ.ក្រ,ក្បាល........) នៅថ្ងៃទី...................................................................................................................................... |
| ២.រយៈពេល..........ថ្ងៃ នៃថ្ងៃប្រគល់ ទទួលផលិតផល, បន្ទាប់ពីថ្ងៃទី........................ ដល់ថ្ងៃទី............................................ | ២.១.ទូទាត់ថ្លៃលើកទីពីរចំនួន....................................................(រៀល) គុណភាពលេខ(១,២,៣) ..........................................ក្នុងបរិមាណផលិតផល.......................................(គ.ក្រ,ក្បាល........) នៅថ្ងៃទី...................................................................................................................................... ២.២.ទូទាត់ថ្លៃលើកទីពីរចំនួន....................................................(រៀល) គុណភាពលេខ(១,២,៣) ..........................................ក្នុងបរិមាណផលិតផល.......................................(គ.ក្រ,ក្បាល........) នៅថ្ងៃទី...................................................................................................................................... |

២.២ វិធីសាស្រ្តទូទាត់ថ្លៃ

២.២.១) ការទូទាត់ថ្លៃផលិតផលធ្វើឡើងតាមការព្រមព្រៀង(តាមរយៈសាច់ប្រាក់ឬធនាគា)

២.២.២) អ្នកទិញអាចទូទាត់ថ្លៃផលិតផលទៅសមាជិកម្នាក់ៗដោយផ្ទាល់ ឬ ទៅតំណាង

២.២.៣) ក្នុងករណីដែលភាគីអ្នកទិញទូទាត់ថ្លៃផលិតផលទៅក្នុងគណនេយ្យធនាគាឬសាច់ប្រាក់នៃស្ថាប័នអង្គការកសិកររួចរាល់នោះ តំណាងស្ថាប័នអង្គការកសិករត្រូវទទួលខុសត្រូវក្នុងការទូទាត់ថ្លៃផលិតផលបន្តទៅដល់រាល់គ្រប់សមាជិកកសិករទាំងអស់វិញ។

២.២.៤) បើសិនជាភាគីអ្នកទិញ មិនព្រមទូទាត់ថ្លៃផលិតផលទៅក្នុងគណនេយ្យធនាគា ឬ មិនទូទាត់ជាសាច់ប្រាក់ផ្ទាល់តាមការព្រមព្រៀង ឬសងមិនគ្រប់ទៅតាមថ្ងៃដែលកំណត់ ដោយយោងទៅតាមការរៀបរាប់ក្នុង ចំនុចលេខ២ កន្លងទៅ នោះភាគីអ្នកទិញសុខចិត្តសង ជម្ងឺចិត្តទៅឲ្យភាគីអ្នកផលិតក្នុងអត្រា (....................)(%) លើបរិមាណដែលទូទាត់ខ្វះ (........................) រហូតដល់ភាគីអ្នកទិញអាចទូទាត់គ្រប់ចំនួនទៅឲ្យភាគីអ្នកផលិត។

**ឧបសម្ព័ន្ធ៥**

កាលកំណត់ និងទីកន្លែង ប្រគល់ ទទួលផលិតផលក្នុងប្រការ ៥ នៃកិច្ចសន្យា

| កាលកំណត់ ការប្រគល់ ទទួល | ចំណាត់ថ្នាក់/គុណភាព /ទំហំ | បរិមាណ (គ.ក្រ) | ទីកន្លែង នៃការប្រគល់ | សំគាល់ |
|---|---|---|---|---|
| | | | | |

ធ្វើនៅ..............ថ្ងៃទី............ខែ.............ឆ្នាំ.........

តំណាងភាគីអ្នកទិញ

តំណាងភាគីអ្នកផលិត

(ស្នាមម្រាមដៃសាមីខ្លួន)

(ស្នាមម្រាមដៃសាមីខ្លួន)

## ឧបសម្ព័ន្ធ ៦

ការអនុវត្តនៅពេលមានករណីប្រធានសក្តិកើតឡើង

បើសិនជាមានករណីប្រធានសក្តិកើតឡើង មុនពេល អំឡុងពេល ឬ ក្រោយពេល ប្រគល់ ទទួលផលិតផល ភាគីទាំងពីរគួរទិញ(ចំពោះភាគីអ្នកទិញ) និង លក់(ចំពោះភាគីអ្នកផលិត) នូវផលិតផលនៅសល់ដែលមានគុណភាពដូចបានព្រមព្រៀងគ្នា ឬ គុណភាពប្រហាក់ប្រហែល ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន ដោយធ្វើការព្រមព្រៀងគ្នាឡើងវិញដូចមានភ្ជាប់ក្នុងតារាងខាងក្រោមៈ

| ដំណាក់កាលប្រគល់/ ដំណាក់កាលទទួល | ចំណាត់ថ្នាក់គុណភាព | គុណភាពប្រហាក់ប្រហែលនៃការប្រគល់ ទទួលផលិតផល | តម្លៃ/គក្រ. (រៀល) | តម្លៃផលិតផលប្រហាក់ប្រហែល (រៀល) | ទីតាំងប្រគល់/ ទទួល | ការទូទាត់ថ្លៃ |
|---|---|---|---|---|---|---|
| រយៈពេលថ្ងៃ.............<br>នៃថ្ងៃប្រគល់ ទទួលផលិតផល,<br>បន្ទាប់ពីថ្ងៃទី...............<br>ដល់ថ្ងៃទី.................. | | | | | | ទូទាត់ថ្លៃលើកទីមួយចំនួន................(រៀល...)<br>(គុណភាពលេខ១, លេខ២, លេខ៣,)............<br>ក្នុងបរិមាណផលិតផល..........(គ.ក្រ, ក្បាល..)<br>នៅថ្ងៃទី......................................................<br>ទូទាត់ថ្លៃលើកទីពីរចំនួន................(រៀល...)<br>(គុណភាពលេខ១, លេខ២, លេខ៣,)............<br>ក្នុងបរិមាណផលិតផល..........(គ.ក្រ, ក្បាល..)<br>នៅថ្ងៃទី......................................................<br>ទូទាត់ថ្លៃលើកទីបីចំនួន................(រៀល...)<br>(គុណភាពលេខ១, លេខ២, លេខ៣,)............<br>ក្នុងបរិមាណផលិតផល..........(គ.ក្រ, ក្បាល..)<br>នៅថ្ងៃទី...................................................... |

ដំណើរការនៃការទូទាត់ថ្លៃគួរអនុវត្តតាមតម្រូវការ និងវិធីសាស្ត្រដែលបានបង្ហាញក្នុងប្រការ៣ នៃកិច្ចព្រមព្រៀង។